# បទបង្ហាញស្តីពី

# ការបញ្ជ្រាបការគ្រប់គ្រងគ្រោះមហន្តរាយ

# នៅក្នុងកម្មវិធី វិមជ្ឈការ និង វិសហមជ្ឈការ

# ក្នុងខេត្តក្រចេះ

## Dissemination of Disaster Management in Decentralization and Deconcentration(D&D)

## Program in Kratie province

ក្រចេះ,ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៩

# មាតិកាបទបង្ហាញ (Presentation Outline)

១-សេចក្តីផ្តើម Introduction

២-ដំណើរការ និងវិធីសាស្រ្តបញ្ជ្រាប Process and Methodology

៣-លទ្ធផល Result

៤- បញ្ហាប្រឈម Issue/Challenge

៥- សន្និដ្ឋាន និងអនុសាសន៍ Conclusion and Recommendation

# ១.សេចក្តីផ្តើម Introduction

- គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្តក្រចេះ បានធ្វើកិច្ចសហការជាមួយគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ដោយមានការឧបត្ថម្ភថវិកា និងបច្ចេកទេស ***ពីមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី (ADPC)*** ចាប់តាំងពី ខែ មករា ឆ្នាំ ២០០៧ ។
- សិក្ខាសាលាថ្នាក់ខេត្តផ្សព្វផ្សាយពីគម្រោង និងការពិគ្រោះយោបល់ពីវិធីសាស្ត្រក្នុងការបញ្ជ្រាបការគ្រប់គ្រងគ្រោះមហន្តរាយទៅក្នុងផែនការឃុំ ។
- វគ្គបណ្តុះបណ្តាលពីការគ្រប់គ្រងគ្រោះមហន្តរាយ និងវិធីសាស្ត្របញ្ជ្រាបដល់អ្នកសម្របសម្រួលខេត្ត —ស្រុកជារៀងរាល់ឆ្នាំ ។
- ការប្រជុំឯកភាពពីវិធីសាស្ត្របញ្ជ្រាបផែនការគ្រប់គ្រងគ្រោះមហន្តរាយទៅក្នុងផែនការឃុំ និងកាកែច្នៃវិធីសាស្ត្រនេះទៅបញ្ជ្រាបគម្រោងអន្តរឃុំទៀតដោយគ.ប្រខេត្ត ។

# ២_ដំណើរការ និងវិធីសាស្ត្របញ្ជ្រាប Process and Methodology

ក-បញ្ជ្រាបទៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និង កម្មវិធីវិនិយោគឃុំ Dissemination into the process of Commune Development Planning (CDP) and Commune Investment Planning (CIP).

ខ-បញ្ជ្រាបទៅក្នុងផែនការគម្រោងអន្តរឃុំរបស់កម្មវិធីសាកល្បង ពង្រឹងតួនាទីថ្នាក់ស្រុក Dissemination into planning of Inter-commune of District Initiative Program (DIP).

# ក. ការបញ្ជ្រាបទៅក្នុង
# ដំណើរការកសាងផែនការអភិវឌ្ឍន៍
# និង
# កម្មវិធីវិនិយោគឃុំ

# វដ្តនៃការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់



# វដ្តនៃកម្មវិធីវិនិយោគឃុំ សង្កាត់



## *លទ្ធផលក្រោយពីបញ្ជ្រាបទៅក្នុងដំណើរការកសាង CDP និង CIP:*

១-រំលេចឡើងឡើងនូវគម្រោងក្នុងការត្រៀមបង្ការ ការឆ្លើយតប និងការស្តារឡើងវិញ ក្នុងតារាង ២.២ សំរាប់ធ្វើការផ្សព្វផ្សាយនៅពេលធ្វើសិក្ខាសាលាសមាហរណកម្ម ផែនការឃុំនៅថ្នាក់ស្រុកជារៀងរាល់ឆ្នាំ ។

២-ទទួលបានគម្រោងក្នុងការត្រៀមបង្ការ ការឆ្លើយតប និងការស្តារឡើងវិញ ក្រោយពីគ្រោះមហន្តរាយ នៅក្នុងសៀវភៅផែនការអភិវឌ្ឍន៍ និង កម្មវិធីវិនិយោគឃុំ ដើម្បីផ្សព្វផ្សាយជាសាធារណៈដល់ ភ្នាក់ងារ ស្ថាបន័ មន្ទីរ សប្បុរសជន អង្គការផ្សេងៗ.. ។ល ។

៣-បន្ថែមខ្លឹមសារនៃការគ្រប់គ្រងគ្រោះមហន្តរាយទៅក្នុងសៀវភៅផែនការអភិវឌ្ឍន៍ និង កម្មវិធីវិនិយោគឃុំ (ដូចជានៅក្នុងមាតិការ: ១.១.ព័ត៌មានសំខាន់ៗរបស់ឃុំ សង្កាត់ និង ១.៣.ស្ថានភាពបច្ចុប្បន្ននិងបញ្ហាប្រឈម ,,,,,,ជាដើម) ។

# ខ~ បញ្ជ្រាបទៅក្នុងផែនការគម្រោងអន្តរឃុំ របស់កម្មវិធីសាកល្បងពង្រឹងតួនាទីថ្នាក់ស្រុក

➢ បញ្ជ្រាបតាមរយៈដំណើការនៃការជ្រើសរើសគម្រោងអន្តរឃុំ នៅថ្នាក់ស្រុក ដែលក្នុងនោះស្រុកត្រូវរកគម្រោងទាំងឡាយណាដែលមានលក្ខណៈជាអន្តរឃុំ ដាក់បញ្ចូលជាមួយគម្រោងអន្តរឃុំដែលឃុំស្នើរមក ។ នៅពេលនោះស្រុកនឹងប្រើប្រាស់ផែនទី និងឯកសារមួយចំនួនដើម្បីជាជំនួយស្មារតីដែលក្នុងនោះ សៀវភៅផែនការត្រៀមបង្ការគ្រោះមហន្តរាយរបស់ស្រុក ត្រូវបានយកមកប្រើប្រាស់សំរាប់វិភាគនិងដាក់ចូលក្នុងគម្រោងអន្តរឃុំ *ដែលគម្រោងទាំងនោះជាប្រភេទគម្រោងគ្រប់គ្រងគ្រោះមហន្តរាយមានលក្ខណៈជាអន្តរឃុំ* ដើម្បីធ្វើការផ្សព្វផ្សាយ គៀងគរធនធាន សំរាប់ជួយគាំទ្រ នៅពេលធ្វើសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ដូចគ្នានឹងគម្រោងឃុំដែរ ។

# ៣-លទ្ធផល

# Result

# ប្រភេទគម្រោង Kinds of Project

✓ **ប្រភេទគម្រោងដែលបានស្នើរដោយគម្រោងឃុំ ឆ្នាំ២០០៨**

១.ស្ពានបឹង.ប្រឡាយ

២.ផ្តល់ម៉ាស៊ីនបូមទឹក

៣.លើក/ជួសជុលទំនប់

៤.ជីកស្រះ.អាង.អូរ.អណ្តូង

៥.បង្កើត ជួសជុលទីទួលសុវត្ថិភាព

៦.ស្នើសុំទូក កាណូត សាឡាងសំរាប់សង្គ្រោះ

៧.ដាំអំពៅព្រៃ ត្រែង ឫស្សី តាមមាត់ច្រាំងទន្លេ

៨.ផ្សព្វផ្សាយជម្ងឺផ្សាសាយបក្សី

៩.បណ្តុះបណ្តាលក្រុមជួយសង្គ្រោះពេលមានគ្រោះមហន្តរាយ

១០.ផ្តល់សម្ភារ:/ថវិកាពេលមានគ្រោះមហន្តរាយ

១១.សង់ទ្វាទឹក.លូសន្ទះទឹក

១២.សង់ជំរកនៅទីទួលសុវត្ថិភាពសំរាប់មនុស្ស សត្វ

១៣.សង់បង្គោលម៉ែត្រសំរាប់វាស់កំពស់ទឹក

១៤.សង់ក្តារព័ត៏មានស្តីពីស្ថានភាពទឹកជំនន់

១៥.ផ្តល់ថ្នាំបង្ការពេលមានទឹកជំនន់

១៦.ផ្តល់ពាងយក្ស...

✓ **ប្រភេទគម្រោងដែលបានស្នើរដោយគម្រោងអន្តរឃុំ ឆ្នាំ២០០៨**

១.ជួសជុល/ស្ពានទំនប់

២.ស្ពានប្រឡាយ.ព្រែក

៣.លើកទំនប់បង្វៀរ

៤.សង់ទំនប់

៥.ជួសជុលទ្វារទឹក

៦.សង់អណ្តូងល្អ

៧.បណ្តុះបណ្តាលដល់ក្រុមសង្គ្រោះពេលមានគ្រោះមហន្តរាយ

៨.សង់អណ្តូងស្នប់

៩.ផ្សព្វផ្សាយជម្ងឺផ្សាសាយបក្សី

១០.ជួសជុលស្ថានីយ៏បូមទឹក និងទរបង្ហូរទឹក

# ប្រភេទគម្រោង Kinds of Project

## ✓ ប្រភេទគម្រោងដែលបានស្នើរដោយគម្រោងឃុំ ឆ្នាំ២០០៩

១.ជីកប្រឡាយ

២.លើក/ជួសជុលទំនប់

៣.ផ្តល់ម៉ាស៊ីនបូមទឹក

៤.ជីកស្រះស្តុកទឹកសំរាប់ស្រោចស្រព

៥.ស្តារប្រឡាយស្រោចស្រព

៦.ស្តារ/ជួសជុលអាងស្តុកទឹក

៧.អប់រំចំណេះដឹងពីជម្ងឺឆ្លង និងវិធានការណ៍ការពារ

៨.អប់រំសុខភាពអនាម័យនៃការប្រើប្រាស់ទឹក

៩.អប់រំចំណេះដឹងទប់ស្កាត់ការរាតត្បាត

១០.ផ្តល់/ផ្គត់ផ្គង់មធ្យោបាយចំរោះទឹកស្អាត

១១.ផ្តល់ពាង/អាងទឹកស្អាតតាមគ្រួសារ

១២.ជីកអណ្តូងស្នប់/លូ

១៣.ផ្តល់ទូកកាណូតជាមធ្យោបាយធ្វើដំណើរ

១៤.ពង្រឹងសមត្ថភាពការពារទឹកជំនន់( ទូក, អាវ, ពោង )

១៥.បង្កើតសហគមន៍ម៉ាស៊ីនបូមទឹក

១៦.ត្រៀមផ្តល់ជំនួយស្បៀង/សម្ភារ:សង្គ្រោះបន្ទាន់

១៧.លើកទីទួលសុវត្ថិភាព/ជំរកបណ្តោះអាសន្ន

១៨.ជួយអន្តរាគមន៍ម៉ាស៊ីនបូមទឹក

១៩. សំណង់បង្ហៀរ

២០.ផ្តល់ថ្នាំក្លរ៉ាមីនសំលាប់មេរោគក្នុងទឹក

២១.បង្កើតសេវាសង្គ្រោះបន្ទាន់

២២.សាងសង់ស្ថានីយ៍បូមទឹក/ផ្តល់ម៉ាស៊ីន

២៣.ពង្រឹងវិធានការណ៍ការពារគ្រោះថ្នាក់ចរាចរ



## ✓ ប្រភេទគម្រោងដែលបានស្នើរដោយគម្រោងអន្តរឃុំ ឆ្នាំ២០០៩

១.សង់សំណង់បង្ហៀរ

២.ជួសជុល/ស្តារទំនប់

៣.ស្តារប្រឡាយ_ព្រែក

៤.សង់អណ្តូងលូ

៥.បណ្តុះបណ្តាលគណ:កម្មការគ្រប់គ្រងគ្រោះមហន្តរាយ

៦.ផ្តល់ធុងចំរោះទឹកស្អាត

៧.ស្តារ/ជីកប្រឡាយ

៨.ចាក់វ៉ាក់សាំងជម្ងឺគោ ក្របី ជ្រូក

៩.សាងសង់លូបង្ហូរទឹកស្រោចស្រព

១០.បណ្តុះបណ្តាល
និងផ្សព្វផ្សាយត្រៀមបង្ការគ្រោះមហន្តរាយទឹកជំនន់

១១.សង់បង្គោលស្ទង់លទឹក_ ក្តារព័ត៌មាន

១២.សង់ទ្វារទឹក

១៣.ស្តារអាងទឹក

# គម្រោងគ្រប់គ្រងគ្រោះមហន្តរាយនៅក្នុងផែនការឃុំឆ្នាំ ២០០៨-០៩




| | គម្រោងឆ្នាំ ២០០៨ | | | គម្រោងឆ្នាំ ២០០៩ | | |
|---|---|---|---|---|---|---|
| | ចំនួនគម្រោងដែលបានស្នើរ | ចំនួនគម្រោងដែលបានគាំទ្រ | ភាគរយគាំទ្រ | ចំនួនគម្រោងដែលបានស្នើរ | ចំនួនគម្រោងដែលបានគាំទ្រ | ភាគរយគាំទ្រ |
| មូលនិធិឃុំ | ១៨៦ | ២៥ | ១៣ ។៤៤ | ៩១ | ៥១ | ៥៦ ។០៤ |

# គម្រោងគ្រប់គ្រងគ្រោះមហន្តរាយនៅក្នុងផែនការគម្រោងអន្តរឃុំ ឆ្នាំ២០០៨_០៩



# ៤_បញ្ហាប្រឈម Issue/Challenge

- ចំណេះដឹង និងសមត្ថភាពក្នុងការបំផុសគំនិតទាក់ទងនឹងការគ្រប់គ្រងគ្រោះមហន្តរាយរបស់មន្ត្រីសម្របសម្រួលខេត្ត-ស្រុកនៅមានកំរិត។
- ការចូលរួមផ្តល់យោបល់ និងការរកដំណោះស្រាយពី គណៈកម្មាធិការកសាងផែនការនិងថវិការឃុំ,សមាជិកគណកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ និងស្រុកនៅមានកំរិត ។
- ការបណ្តុះបណ្តាលទាក់ទងនឹងការគ្រប់គ្រងគ្រោះមហន្តរាយមានរយៈពេលខ្លី និង បន្ទាន់ពេក។

# ៥. សន្និដ្ឋាន និង អនុសាសន៍ Conclusion and Recommendation

| សន្និដ្ឋាន | អនុសាសន៍ |
|---|---|
| ▪ ចំនួនប្រភេទគម្រោងដែលបានសើរឡើងដោយឃុំ និងស្រុកមាន ការកើនឡើងជាលំដាប់ពី ១៦-២៣ គម្រោងចំពោះគម្រោងឃុំ និងពី ១០-១៣ ចំពោះកម្រោងអន្តរឃុំ ។ តែផ្ទុយទៅវិញ ចំនួនគម្រោងបែរជាមានការថយចុះពី ១៨៦-៩១ ចំពោះគម្រោង ឃុំ ។ ឯចំនួនគម្រោងអន្តរឃុំ នៅតែកើនឡើងពី ៣៣-៣៥ ។<br>▪ ភាគរយនៃការគាំទ្រគឺមានការកើនឡើងពី១ឆ្នាំ ទៅ ១ឆ្នាំ ។ សំរាប់គម្រោងឃុំពី ១៣-៥៦ ភាគរយ និងគម្រោងអន្តរឃុំពី ១៨-២៥ ភាគរយ ។<br>▪ ឃុំនិងស្រុកបានទទួលគម្រោងគ្រោះមហន្តរាយមួយចំនួនដាក់ចូលទៅក្នុងសៀវភៅផែនការរបស់ខ្លួន និងដាក់បង្ហាញដើម្បីស្វែងរកការគាំទ្រនៅពេលធ្វើសិក្ខាសាលាសមាហរណកម្មផែនការឃុំនៅថ្នាក់ស្រុក និងទទួលបានការគាំទ្រពីបណ្ដា ស្ថាបន័ មន្ទីរអង្គការ.,, ។ល ។ តែលទ្ធភាពគាំទ្រនៅមានចំនួនតិចនៅឡើយ មិនទាន់បានឆ្លើយតបតាមតម្រូវការរបស់ប្រជាពលរដ្ឋ<br>▪ ចំណេះដឹងពីគ្រោះមហន្តរាយរបស់មន្ត្រីសម្របសម្រួលខេត្ត-ស្រុក ,គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ និង ស្រុក នៅមានកំរិតនៅឡើយ ។<br>▪ វិធីសាស្ត្របញ្ច្រាបមានលក្ខណៈសាមញ្ញ អាចទទួលយកបាន ។ | ▪ សូមអោយម្ចាស់មូលនិធិ អង្គការ ស្ថាប័ន សប្បុរសជន មេត្តាជួយបន្ដរ និងបង្កើនការគាំទ្រដល់គម្រោងអភិវឌ្ឍឃុំ ថែមទៀត ព្រោះវាជាគម្រោងដែលកើតចេញពីមូលដ្ឋានពិត១ដែលឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋ ។<br>▪ ការបណ្ដុះបណ្ដាលដល់គណកម្មការគ្រប់គ្រងគ្រោះមហន្តរាយឃុំ និងមន្ត្រីសំរបសំរួលខេត្ត ស្រុក គួរត្រូវបានធ្វើឡើងថែមទៀត ។<br>▪ កម្មសិក្សាគួរត្រូវបានធ្វើដើម្បីដកស្រង់បទពិសោធន៏ពីគ្នាទៅវិញទៅមក ។ |

# សូមអរគុណ

# Thank You